# អរិយធម៌ខាតាប ( Carthage civilization)

ខាតាប (Carthage) គឺជាអរិយធម៌មួយដែលកើតចេញពីអរិយធម៌ ផូនីស្យា ហើយក៏ជាអតីតទីក្រុងនៃអរិយធម៌ផូនីស្យាដែរ។[១] សព្វថ្ងៃជាប្រទេសទុយនេស៊ី (Tunisia) ដែលស្ថិតនៅទ្វីបអាហ្វ្រិចខាងជើង។ ចំពោះឈ្មោះ ខាតាប (Carthage) នេះវិញ មានន័យថា *Kart-hadasht* ឬ ទីក្រុងថ្មីមួយ (New Town)[២] និងនៅភាសាក្រិចបុរាណហៅទីក្រុងនេះថា *Karchedon* និងភាសារ៉ូម៉ាំងបុរាណវិញហៅថា *Carthago*។[៣]

អរិយធម៌នេះកកើតឡើងនៅស.វ.ទី៩មុនគ.ស. ដែលនៅមុនពេលនៃអរិយធម៌រ៉ូមបុរាណរីកចម្រើនខ្លាំង ខាតាប គឺធ្លាប់ជាទីក្រុងដែលមានឥទ្ធិពលខ្លាំងក្លានៅក្នុងតំបន់ និងបរិវេណនៃមហាសមុទ្រមីឌីទែរ៉ាណេ។[៤] នៅក្នុងសម័យកាលនៃផូនីស្យា ខាតាប គឺជាទីក្រុងដែលមានទ្រព្យសម្បត្តិ និងសំខាន់ជាងគេ ដោយសារតែជាចំណុចបណ្តុំនៃការធ្វើជំនួញពាណិជ្ជកម្មនៅក្នុងតំបន់សម័យមីឌីទែរ៉ាណេ។

នៅក្នុងប្រវត្តិសាស្ត្រនៃខាតាបត្រូវបានបែងចែកចេញជា៥សម័យកាល៖ ១).សម័យខាតាបបុរាណ (Ancient Carthage -Punic Republic) (ឆ្នាំ៨១៤-១៤៦ មុនគ.ស.), ២).សម័យរ៉ូម៉ាំងខាតាប (Roman Carthage) (ឆ្នាំ ១៤៦មុនគ.ស រហូតដល់៤៣៩នៃគ.ស.), ៣).សម័យវ៉ាន់ដាលខាតាប(Vandal Carthage) (ឆ្នាំ៤៣៩គ.ស. រហូតដល់៥៣៤គ.ស.), ៤).សម័យប៊ីហ្សង់ទិនខាតាប( Byzantine Carthage)(ឆ្នាំ៥៣៤គ.ស. រហូតដល់៦៩៨) និង ៥).សម័យម៉ូស្លីមខាតាប (Muslim Arab Carthage)(ឆ្នាំ៦៩៨គ.ស. រហូត ១២៧០នៃគ.ស.)។[៥]

អរិយធម៌នេះ មានការទទួលឥទ្ធិពលច្រើនពីសំណាក់អរិយធម៌ក្បែរខាង ទើបការបែងចែកសម័យកាលនៅក្នុងអរិយធម៌នេះ គឺបែងចែកទៅតាមការគ្រប់គ្រងពីវប្បធម៌ផ្សេងៗ។

---

[១] https://ams.com.kh/khmercivilization/detail/18145

[២] https://www.worldhistory.org/carthage/

[៣] ibid

[៤] https://www.nationalgeographic.org/encyclopedia/carthage/

[៥] https://www.worldhistory.org/carthage/

អត្ថបទដោយ៖ អេង តុលា

*រីឯប្រព័ន្ធរដ្ឋបាលនៃអរិយធម៌នេះ គឺជាការគ្រប់គ្រងដោយមនុស្សតែម្នាក់ (ស្តេច, មេដឹកនាំ) ដែលហៅថា* Monarchy*។ ការគ្រប់គ្រងនេះគឺខុសពីនៅអរិយម៌ផូនីស្យា ដែលជាការគ្រប់គ្រងដោយផ្នែកផ្សេងៗគ្នា។ ចំពោះសំណង់ស្ថាបត្យកម្ម វប្បធម៌ និងសាសនា នៃអរិយធម៌ខាតាចនេះគឺទទួលឥទ្ធិពលទាំងស្រុងពីអរិយធម៌ក្រិច រ៉ូមាំង និងប៊ីហ្សង់ទិន ដូចនៅអរិយធម៌ផូនីស្យាដែរ ដោយនៅទីនេះវិញក៏មានសាងសង់សំណង់* Colosseum *ដូចនៅរ៉ូមដែរ និងជាពិសេសនោះគឺ សសរទាំង៣នៃរចនាបទនៅក្រិច ឬរ៉ូមាំងសម័យបុរាណ។*

*ផ្នែកសិល្ប: ជាពិសេសរូបបដិមា/រូបចម្លាក់ និងវត្ថុសិល្ប:ផ្សេងៗទៀត គឺទទួលឥទ្ធិពលពីអរិយធម៌ចំរុះដូចជា អេហ្ស៊ីប , ក្រិច ,ផូនីស្យា , រ៉ូមាំង ជាដើម។*[៦]

*ដូចបានបង្ហាញនៅខាងលើពីសម័យកាលនៃខាតាចហើយថា អរិយធម៌ខាតាចបុរាណត្រូវបានដួលរលំនៅអំឡុងឆ្នាំ១៤៦មុនគ.ស. និងបន្តគ្រប់គ្រងដោយអរិយធម៌ផ្សេងដូចជា រ៉ូមាំង វ៉ានដាល និងចុងក្រោយដោយម៉ូស្លីម ឬ អាចហៅម្យ៉ាងទៀតថា អាណាចក្រអូតូម៉ង់ ដែលបានគ្រប់គ្រង់លើអរិយធម៌ប៊ីហ្សង់ទីន និងទឹកដីអរិយធម៌ខាតាចបុរាណនេះ ។*

*អាណាចក្រខាតាចបុរាណ គឺប្រៀបបានដូចការសំណង់បុរាណចាស់នៅក្នុងប្រវត្តិសាស្ត្រ និងជាគ្រឹះនៃការសិក្សាពីប្រទេសទុយនេស៊ីដែរ។ ស្ថានីយ៍ខាតាច* (Carthage site) *នេះត្រូវបានចូលជាសម្បត្តិបេតិកភណ្ឌពិភពលោកនៅក្នុងឆ្នាំ១៨៨៥ ៕*

---

៦ https://www.worldhistory.org/carthage/

*អត្ថបទដោយ៖ អេង តុលា*




រូបលេខ១៖ ផែនទីទឹកដី នៃអរិយធម៌ខាតាច
ប្រភព៖ www.worldhistory.com



រូបលេខ២៖ សំណង់ទីក្រុងខាតតាចបច្ចុប្បន្ន
ប្រភព៖ www.worldhistory.com

អត្ថបទដោយ៖ អេង តុលា



រូបលេខ៣៖ សសរនៃឥទ្ធិពលក្រិច
ប្រភព៖ www.worldhistory.com



រូបលេខ៤៖ សំណង់ស្ថាបត្យកម្មក្រិចនៅក្នុងតំបន់
ប្រភព៖ www.worldhistory.com

អត្ថបទដោយ៖ អេង តុលា





រូបលេខ ៥៖  ចម្លាក់រូបមនុស្ស និងរូប mosaic, ៦៖ កក់មាស ដែលមានរូបមនុស្ស និងសត្វសេះ

ប្រភព៖ www.worldhistory.com , https://www.britannica.com/



រូបលេខ ៦៖ កក់មាស ដែលមានរូបមនុស្ស និងសត្វសេះ

ប្រភព៖ www.worldhistory.com , https://www.britannica.com/

អត្ថបទដោយ៖ អេង តុលា

## ឯកសារយោង


https://ams.com.kh/khmercivilization/detail/18145

https://www.worldhistory.org/carthage/

https://www.nationalgeographic.org/encyclopedia/carthage/

https://www.britannica.com/

https://whc.unesco.org/en/list/37


អត្ថបទដោយ៖ អេង តុលា